# ពលរដ្ឋជួបប្រជុំគ្នា សំដែងពីកង្វល់នៃការបំផ្លាញព្រៃឡង់

Written by អ៊ឹង ប៊ុនថន Thursday, 23 June 2011 04:00

There are no translations available.

ប្រជាពលរដ្ឋប្រមាណ ៣០០នាក់ មកពីព្រំប្រទល់ខេត្តពីរ គឺស្ទឹងត្រែង និងក្រចេះ ដែលជាប់នឹងតំបន់ព្រៃឡង់ ព្រមទាំងពលរដ្ឋនៃខេត្តមួយចំនួនទៀត ដែលកំពុងទទួលរងការរំលោភសិទ្ធិមនុស្ស និងការរំលោភសិទ្ធិដីធ្លីជួបពិភាក្សាគ្នា នៅក្នុងវេទិកាសិទ្ធិមនុស្ស នៅថ្ងៃព្រហស្បត៍ទី២៣ ខែមិថុនា ឆ្នាំ២០១១ នេះ។

សេចក្ដីប្រកាសព័ត៌មានរបស់មជ្ឈ មណ្ឌលសិទ្ធិមនុស្សកម្ពុជា បានឱ្យដឹងថា វេទិកាក្រោមប្រធានបទ ”សិទ្ធិមនុស្ស និងការអភិវឌ្ឍន៍ ” នេះ រៀបចំឡើងនៅភូមិចង្អប ឃុំក្បាលដំរី ស្រុកសំបូរ ខេត្តក្រចេះ នៅថ្ងៃទី២៣ខែមិថុនានេះ។

ការរៀបចំវេទិកាសិទ្ធិមនុស្សលើកទី២ នៅតំបន់ព្រៃឡង់នេះ ធ្វើឡើងចំពេលដែលមានសេចក្ដីរាយការណ៍ពីបណ្ដាញសហគមន៍ព្រៃ ឡង់ថា ព្រៃឡង់ដ៏មានសារៈសំខាន់ នៅជាប់ខេត្តចំនួន៤ គឺកំពង់ធំ ព្រះវិហារ ក្រចេះ និងស្ទឹងត្រែងនេះ កំពុងរងការកាប់បំផ្លាញយ៉ាងធ្ងន់ធ្ងរ ខណៈក្រុមហ៊ុនដែលទទួលបានដីសម្បទានសេដ្ឋកិច្ចពីរដ្ឋ ចាប់ផ្ដើមធ្វើសកម្មភាពអភិវឌ្ឍន៍។

មន្ត្រីសម្របសម្រួល នៃមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា លោក ឈឹម សារុធ ថ្លែងថា ពលរដ្ឋបានលើកឡើងនូវចំណុចជាច្រើន ទាក់ទងនឹងការរំលោភបំពានដីធ្លីជនជាតិដើមនៅតំបន់នោះ ៖” *មានចូលរួមទាំងមេភូមិ មេឃុំ អភិបាលស្រុក អភិបាលខេត្ត ប៉ុន្តែប្រជាពលរដ្ឋគាត់លើកចំនុចក្ដៅៗពាក់ព័ន្ធជនជាតិដើម ភាគតិច ត្រូវបានក្រុមហ៊ុនទៅបោះបង្គោល ទៅឈូសឆាយ គេរំលោភយកដីស្រែដីចំការពួកគាត់” ។*

ថ្មីៗនេះ បណ្ដាញសហគមន៍ការពារព្រៃឡង់ ប្រហែល២០០នាក់ បានជួបជុំគ្នាតវ៉ានៅទីលានប្រជាធិបតេយ្យ ក្នុងរាជធានីភ្នំពេញ ដើម្បីឲ្យរដ្ឋាភិបាលកម្ពុជា ដកហូតដីសម្បទានព្រៃឡង់ ទៅឲ្យក្រុមហ៊ុនវៀតណាម វិយោគនោះមកវិញ ដោយសំអាងថា បានធ្វើឲ្យពលរដ្ឋនៅតំបន់នោះបាត់មុខរបរប្រចាំថ្ងៃ និងបានកាប់បំផ្លាញព្រៃឈើដ៏មានតម្លៃ នាំឲ្យខូចបរិស្ថាន និងបំផ្លាញធនធានជីវចម្រុះ នៅតំបន់ព្រៃឡង់នោះ។

រហូតមកដល់ពេលនេះ មិនទាន់មានប្រតិកម្មពីរដ្ឋាភិបាលកម្ពុជានូវឡើយទេ។

ប៉ុន្តែកាលពីខែមេសាឆ្នាំ២០១១នេះ រដ្ឋាភិបាលកម្ពុជា បានដកហូតអាជ្ញាប័ណ្ណ ដីសម្បទានសេដ្ឋកិច្ចពីក្រុមហ៊ុនឯកជន ប្រមាណ ១២ក្រុមហ៊ុន បន្ទាប់ពីរកឃើញថា ក្រុមហ៊ុនទាំងនោះ បានកាប់បំផ្លាញព្រៃឈើ ដោយគ្មានការអភិវឌ្ឍន៍៕